ស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា
ប្រចាំប្រទេសអង់គ្លេស ដាណឺម៉ាក ហ្វាំងឡង់ អៀរឡង់ ន័រវេ ស៊ុយអែត
និងអេត្យូពី

**Royal Embassy of Cambodia**
*to UK – Denmark – Finland – Ireland – Norway – Sweden*
*& Ethiopia*

*The Ambassador*
*& Permanent Representative of Cambodia to African Union*

**ជូនចំពោះ**

**លោកស្រី** Sobopha Owen

ប្រធានសមាគមនី CASUNIK នៅទីក្រុងឡុងដ៍

**លោកស្រីជាទីរាប់អាន**

នៅក្នុងឱកាសដ៏នក្ខត្តឬក្សថ្លៃថ្លា នៃថ្ងៃ**បុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំរោង ចត្វាស័ក ព.ស ២៥៥៦** តាងនាមអោយមន្ត្រីស្ថានឯកអគ្គរាជទូតកម្ពុជា នៅទីក្រុងឡុងដ៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ និងភរិយា សូមប្រសិទ្ធិពរជ័យ បវរសួស្តី សិរីមង្គល និងវិបុលសុខ ជូនចំពោះលោកស្រី និងជនជាតិខ្មែរទាំងអស់ដែលកំពុងរស់នៅក្នុងប្រទេសអង់គ្លេស និងសូមផ្តាំផ្ញើនូវការនឹករលឹកដ៏ជ្រាលជ្រៅបំផុត អំពីយើងខ្ញុំ ។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះលោកស្រី ក្នុងកិច្ចខិតខំប្រឹងប្រែងអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងបទពិសោធន៍ក្នុងការដឹកនាំសមាគមនី CASUNIK អស់រយៈពេល ៤ ឆ្នាំកន្លងមក និងសូមវាយតម្លៃខ្ពស់ចំពោះស្នាដៃ និងសមិទ្ធិផលនានាដែលសំរេចបានក្រោមការដឹកនាំដ៏ឈ្លាសវៃ និង ប៉ិនប្រសព្វរបស់លោកស្រី ជាពិសេសការថែរក្សា និងលើកស្ទួយវិស័យវប្បធម៌ និងសិល្បៈប្រពៃណីជាតិខ្មែរ ដែលជាកេរ្តិ៍មរតកពីបរមបូរាណរបស់ដូនតាខ្មែរយើង ។

ជាងនេះទៅទៀត ខ្ញុំសូមបន្តការគាំទ្របេក្ខភាពលោកស្រីជារៀងរហូតក្នុងការដឹកនាំសមាគមនី CASUNIK ដែលប្រកបទៅដោយឆន្ទៈម្ចាស់ការ ឧស្សាហ៍ព្យាយាម និងគុណធម៌ដ៏ល្អប្រពៃ **និងសូមផ្តល់នូវការឧបត្ថម្ភប្រចាំឆ្នាំនូវទឹកប្រាក់ចំនួន ១000 ផោន ( មួយពាន់ផោន ) ដើម្បីយកទៅប្រើប្រាស់ជាប្រយោជន៍ និងសំរាប់ការចាំបាច់របស់សមាគមនី** ហើយស្ថានទូតសង្ឃឹមថា លោកស្រីនឹងជាប់ឆ្នោតនៅអាណត្តិក្រោយជាប្រធានសមាគមនី CASUNIK បន្តទៀត ដែលការបោះឆ្នោតនឹងប្រព្រឹត្តទៅនៅខែតុលា ឆ្នាំ ២០១២ ខាងមុខនេះ ។

ជាថ្មីម្តងទៀតខ្ញុំសូមជូនពរដល់លោកស្រី និងជនជាតិខ្មែរទាំងអស់ដែលរស់នៅក្នុងប្រទេសអង់គ្លេស សូមប្រកបទៅដោយសុខភាពល្អបរិបូណ៌ កំលាំងពលំមាំមួន បញ្ញាវាងវៃ និងអាយុយឺនយូរ និងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **លោកស្រី** ទទួលនូវរាប់អាន អំពីយើងខ្ញុំ និងសូមជួយផ្សព្វផ្សាយនូវខ្លឹមសារលិខិតនេះជូនដល់ជនជាតិខ្មែរទាំងអស់ដែលកំពុងរស់នៅក្នុងប្រទេសអង់គ្លេស កុំបីខាន ។

ធ្វើនៅទីក្រុងឡុងដ៍. ថ្ងៃទី 13 ខែមេសា ឆ្នាំ ២០១២

Ha ...

**ហោ ណាំបូរ៉ា**

64 Brondesbury Park, Willesden Green, London NW6 7AT

Tel: 020 8451 7850 Fax: 020 8451 7594 Web-site: www.cambodianembassy.org.uk E-mail:cambodianembassy@btconnect.com